ពិភពរឿងនិទាន

The World of Stories

# ក្រុងសុភមិត្រ

# KRONG SOPHEAKMIT



សៀវភៅជាឃ្លាំងនៃចំណេះដឹង

Books are the source of knowledge

ជាយូរអង្វែងណាស់មកហើយ មានព្រះមហាក្សត្រមួយអង្គព្រះនាមព្រះបាទ **ក្រុងសុភមិត្ត** សោយរាជ្យនៅចម្បាកនគរ។ ទ្រង់មានព្រះមហេសីព្រះនាម **កេសិនី** មានព្រះរាជបុត្រពីរព្រះអង្គ។ ព្រះរាជបុត្រច្បងព្រះនាម **ជ័យសែនកុមារ** ព្រះរាជបុត្រប្អូនព្រះនាម **ជ័យទត្តកុមារ**។ កាលណោះព្រះបាទ **ក្រុងសុភមិត្ត** មានព្រះអនុជមួយអង្គព្រះនាម **អសុភមិត្ត** មានតំណែងជាឧបរាជ។ ចំណេរកាលក្រោយមក **អសុភមិត្ត** មានគំនិតក្បត់ចង់ដណ្តើមរាជសម្បត្តិពីព្រះរាម ហើយលើកទ័ពទៅព័ទ្ធក្រុងចម្បាកនគរ។



Long, long time ago, there was a king named Preah Bath Krong Spheakmit, who reigned in Champak Kingdom. The king had a wife named Kesiny and two sons. The elder son was named Cheysen Kumar and the younger, Cheytot Kumar. King Sopheakmit had a younger brother, AkSopheakmit, who served as a lord. Afterward, AkSopheakmit planned to betray his brother to seize the throne and deployed his soldiers around Champak Kingdom.



កាលណោះ មានអាមាត្យម្នាក់ឡើងមកក្រាបទូលព្រះបាទ **ក្រុងសុភមិត្រ** ឱ្យទ្រង់បានជ្រាបអំពីដំណើរជ្រែករាជ្យនៃ **អសុភមិត្រ** ជាព្រះអនុជគ្រប់ប្រការ។ ព្រះបាទ **ក្រុងសុភមិត្រ** ទ្រង់ព្រះចិន្តាថា "ប្រសិនបើអង្គអញចេញទៅច្បាំងតទល់នឹងព្រះអនុជ មុខជាព្រះញាតិវង្សព្រមទាំងអាណាប្រជានុរាស្ត្រ និងសេនាទាហានវិនាសអន្តរាយអស់ច្រើនជាក់ជាពុំខាន បើដូច្នេះអញគួរតែដោះខ្លួនគេចចេញអំពីព្រះរាជវាំងក្នុងរាត្រីនេះ"។ ទើបស្តេចត្រាស់លាព្រះអគ្គមហេសីព្រមទាំងព្រះរាជបុត្រទាំងពីរ។ ឯព្រះនាង **កេសិនី** ជាស្ត្រីស្មោះភក្តីចំពោះព្រះរាជស្វាមីមិនព្រមនៅក្នុងព្រះរាជវាំងឡើយ ទើបព្រះនាងទូលព្រះស្វាមីថា "ខ្ញុំម្ចាស់សុខចិត្តស្លាប់ជាមួយនឹងព្រះអង្គទោះជាលំបាកវេទនាយ៉ាងណាក៏ដោយ តែខ្ញុំម្ចាស់ពុំព្រមរស់នៅឃ្លាតឆ្ងាយព្រាត់ប្រាសអំពីព្រះអង្គឡើយ ខ្ញុំម្ចាស់សុំនាំកូនទាំងពីរទៅតាមព្រះស្វាមីដែរហើយ"។

At that time, a royal servant came to tell King Sopheakmit about his brother's betrayal plan to occupy the throne. "If I waged war against my younger brother," said King Sophakmitr, "many of my royal families, people and soldiers will suffer and die and therefore, I should escape from the royal palace tonight." Then, the king said goodbye to his wife and his two sons. Kesiny, who was a faithful wife, refused to stay in the palace. "My dear, though it is in the hardship, I agree to die with you," she said, "I cannot separate from you and I request that we take the two sons with us."

ព្រះមាតាទ្រង់ព **ជ័យទត្តកុមារ** ព្រះបិតាទ្រង់ព **ជ័យសែនកុមារ** ។ ទ្រង់ស្ពាយស្បៀងភៀសព្រះកាយចាកចេញអំពីព្រះនគរក្នុងរាត្រីនោះ ដោយសេចក្តីក្តុកក្តួលក្នុងព្រះឱរា។ ស្តេចត្រាច់ចរទៅដោយលំដាប់ដរាប ទៅដល់ឆ្នេរទន្លេមួយអន្លើ ទើបទ្រង់ឈប់សម្រាកក្រោមដើមទន្លាប់មួយដើម។ ព្រះអង្គមានព្រះឱង្ការថា "យើងឆ្លងទន្លេនេះទៅទាំងបួននាក់ពុំបានទេ ព្រោះទឹកមានជម្រៅជ្រៅ។ ដូច្នេះបងនឹងចម្លងអូនទៅមុន សឹមវិលមកចម្លងបុត្រជាក្រោយ"។ ហើយទ្រង់ហែលចម្លងព្រះមហេសីទៅដាក់នៅឯត្រើយម្ខាង។



ក្នុងពេលខណៈដែល **ក្រុងសុភមិត្រ** កំពុងចម្លង
ព្រះរាជទេវីនោះ ក៏មានព្រានមច្ឆាពីរនាក់អុំទូក
នេសាទមកតាមឆ្នេរទន្លេបានឃើញ
កុមារតូចៗក៏នាំគ្នាពក្មេងៗទាំង
ពីរនាក់នោះយកទៅដាក់ក្នុង
ទូកនាំទៅផ្ទះរបស់ខ្លួន។



The mother carried Cheytot Kumar and the father held Cheysen Kumar. The king with a bag full of food escaped that night from his kingdom, feeling very painful in his heart. The king and his wife, as well as his sons wandered further and further and reached a river, and then they had a rest under a Tonleab (a kind of tree). The king said, "Four of us cannot cross this river at the same time in deep water, so I will take you to the other side first and then come back to take our two sons." The king then carried his wife to the other side and told his wife to stay there. While King Sopheakmit was swimming, there were two fishermen who were rowing the boat along the river, saw the two sons and then took them to their own home right away.

បន្ទាប់ពីព្រះរាជាចម្លងព្រះមហេសីដាក់នៅត្រើយម្ខាងរួចហើយ ទ្រង់ក៏ហែលត្រលប់មករកព្រះរាជបុត្រវិញ។ តែគួរឱ្យចម្លែកណាស់ ពេលដែលទ្រង់មកដល់ ទ្រង់ពុំបានឃើញព្រះរាជកុមារទាំងពីរអង្គឡើយ ក៏ទ្រង់ព្រះជង្ហ្គាយហៅរត់រកព្រះរាជបុត្រក្នុងព្រៃព្រឹក្សាត្រាតែភ្លឺស្វាងឡើង នៅតែពុំឃើញព្រះរាជកុមារទៀត ទ្រង់ព្រះកន្សែងសោយសោករហូតសន្លប់បាត់ស្មារតីនៅទីនោះ។



After getting his wife to stay at the other side, the king returned to his sons. Amazingly when the king arrived, his sons were not there, so he was shocked and he shouted for them in the forest until it was dawn in the morning, but his sons remained invisible. The king was sobbing and wailing so much that he became fainted there.

ចំណែកព្រះនាង **កេសិនី** វិញ រង់ចាំព្រះស្វាមីតាំងពីយប់រហូតដល់ភ្លឺ។ ជួនជាពេលនោះមានសំពៅមួយបើកមកតាមទន្លេធំ។ នាយសំពៅបានឃើញព្រះនាងនៅតែអង្គឯង ក៏ចូលសំពៅទៅនិយាយបង្ខំឱ្យព្រះនាងទៅជាមួយនឹងពួកគេ។ គ្រានោះព្រះនាងទ្រង់ព្រះកន្សែងសោកបោកប្រាណស្ទើរបែកព្រះកាយ។ ព្រះឱរាស្ទើរតែបែកសញ្ញែកចេញជាប្រាំពីរភាគ ដោយព្រះនាងទ្រង់នឹករលឹកដល់ព្រះរាជបុត្រសម្លាញ់ទាំងពីរ និងព្រះស្វាមីឥតល្ហែល្ហើយ។



As for Princess Kesiny, she waited for her husband until the next morning. Accidentally, there was junk sailing along the river. The merchant of the junk, who saw Kesiny staying alone, went down to her and forced her to go with them. At that moment, Princess Kesiny was whining; her body was almost badly injured. Her heart was nearly broken into seven parts, since she was always missing her husband and sons.



លុះព្រះបាទ **ក្រុងសុភមិត្រ** ភ្ញាក់ស្មារតីឡើងវិញ ទ្រង់កាត់ព្រះទ័យសោកស្តាយព្រះរាជបុត្រ ហើយត្រឡប់ទៅរកព្រះមហេសីវិញមានសេចក្តីសង្ឃឹមថា នឹងបានជួបមហេសីដើម្បីថ្លែងប្រាប់អំពីដំណឹងដ៏សែនអាក្រក់នេះ។ ព្រះអង្គហែលទឹកឆ្លងទន្លេដោយព្រះទ័យអស់សង្ឃឹម។ លុះឡើងពីទឹកស្ទុះសំដៅទៅរកមើលក្រោមដើមឈើដែលព្រះនាងគង់ចាំ តែមិនបានឃើញព្រះនាងសោះ ទ្រង់ស្ទុះរត់រកព្រះនាងសព្វទីកន្លែង តែមិនបានជួបប្រទះនឹងនាងឡើយ។ ទ្រង់រឹតតែអស់សង្ឃឹមជាខ្លាំង។ បន្ទាប់ពីបាត់កូនហើយបែរជាមកព្រាត់ប្រពន្ធថែមទៀត។ ទ្រង់សោយសោកសង្រេងសង្រៃកាន់តែខ្លាំងឡើង ក៏ទ្រង់ដួលសន្លប់នៅទីនោះម្តងទៀត។

King Krong Sopheakmit regained consciousness, relieved from the pain and went back to his wife, hoping to tell her the bad news of the sons. The king hopelessly swam across the river. Trudging out of water and walking to a place under a tree where his wife was to wait for him, the king didn't find his wife. He looked for her everywhere, but didn't see her. The king felt even more hopelessness after losing his sons and then his wife. He became more depressed, fell to the ground and lost consciousness again.



លុះព្រះអង្គភ្ញាក់ស្មារតីឡើងវិញ ក៏ទ្រង់ព្រះកន្សែងរវើរវាយស្មើរតែឆ្កួតវង្វេង។ ស្ដេចត្រាច់ពីទីនោះយាងចេញទៅមុខទៀតតែអង្គឯង ព្រះភក្ត្រស្រពាប់ស្រពោនគួរឱ្យសង្វេក។ ស្ដេចត្រាច់ដរាបដល់នគរតក្កសិលា ហើយទ្រង់យាងចូលក្នុងឧទ្យាន ទ្រង់ផ្ទំសម្រាកព្រះកាយពលលើថ្មមង្គលសិលាក្រោមដើមរាំងមួយដើម។ កាលណោះ ព្រះមហាក្សត្រនៃនគរតក្កសិលាទ្រង់សោយទីវង្គតប្រាំពីរថ្ងៃហើយ តែទ្រង់គ្មានព្រះរាជបុត្រមួយអង្គសោះ ទើបអាមាត្យសព្វមុខមន្ត្រីធ្វើពិធីផ្សងបុស្សរថតំកល់គ្រឿងបញ្ចកកុធភណ្ឌ រួចដង្ហែចេញទៅតាមក្រោយបុស្សរថព្រមទាំងតូរ្យតន្ត្រីផង។ បុស្សរថបានសំដៅទៅឧទ្យានធ្វើប្រទក្សិណមង្គលសិលារួចស្ថិតនៅស្ងៀម ពួកភ្លេងក៏ប្រគំបទភ្លេងឡើង។ លុះព្រះបាទ **ក្រុងសុភមិត្រ** តើនឡើងបានត្រាស់សួរហេតុផលចំពោះពួកគេ។ អាមាត្យមន្ត្រីទាំងនោះបានក្រាបទូលអញ្ជើញព្រះអង្គឱ្យឡើងគ្រងរាជ្យនៅនគរតក្កសិលា។

When the king woke up, he cried and deliriously talked like crazy. He continued his journey alone; his face was full of sorrow. He wandered and finally reached Takaksila Kingdom. He went into the park and slept on a lucky stone under a Raing tree (kind of tree). At that time, the king of Takaksila Kingdom had died seven days ago, he had no child at all, so the royal servants and officials held a pray ceremony with five royal sacred instruments in a white horse cart to search for a new king and the procession was accompanied by the music. This white horse cart went towards the park walked around the lucky stone and stopped, while seeing this event, the musicians started playing immediately. When he was awaked, King Krong Sopheakmit asked what happened. The royal servants and officials respectfully invited and assigned him to reign Takaksila Kingdom.

ស្លេះត្រឹមនេះ និយាយពីព្រានមច្ឆាពីរនាក់ដែលចាប់ក្មេងៗនោះទៅ ក៏ខំចិញ្ចឹមបីបាច់ថែរក្សាពួកគេរហូតដល់ធំពេញវ័យ។ ព្រានមច្ឆាក៏នាំពួកគេទៅថ្វាយស្ដេចតក្កសិលាធ្វើជាមហាតលិក។ ព្រះចៅក៏ទ្រង់ប្រោសប្រណីចំពោះអ្នកទាំងពីរនេះណាស់ ប៉ុន្តែទ្រង់ពុំបានដឹងថា ពួកគេជាព្រះរាជបុត្ររបស់ទ្រង់ឡើយ។ ចំណែក **ជ័យសែន** វិញ ស្គាល់ព្រះបិតាច្បាស់ណាស់ តែគេមិនធ្វើជាស្គាល់ទ្រង់ឡើយ។



Talking about the two fishermen, who brought the two boys, they tried their best to raise the children until they grew up. The fishermen then took them to the king of Takaksila Kingdom to work as royal servants. The king was very kind to the two young boys, but did not know that they were his children. As for Cheysen, he clearly recognized his father but pretended not to recognize him.

ចំណែកឯនាយសំពៅដែលនាំព្រះនាង **កេសិនី** ទៅនោះ មានបំណង ចង់រួមវាសនានឹងព្រះនាងណាស់ ប៉ុន្តែដោយតេជៈសច្ចៈនឹងក្ដីស្វាមីភក្ដិ ចំពោះព្រះស្វាមី ព្រមទាំងចេស្ដាបារមីនៃព្រះបាទ **ក្រុងសុភមិត្រ** ធ្វើឱ្យ នាយសំពៅមិនអាចចូលជិតព្រះនាងបានឡើយ ថែមទាំងមានសេចក្ដីគោរព កោតខ្លាចចំពោះព្រះនាងទៀតផង។



The merchant, who abducted Princess Kesiny, was really willing to take her to be his wife, but, because the faithfulness and loyalty to her husband and the great divine power of the king made the merchant not able to come near her, on the contrary he was afraid and respected her.

កាលណោះនាយសំពៅបានទៅធ្វើជំនួញនៅក្រុងតក្កសិលា។ ព្រះរាជាទ្រង់មានព្រះបន្ទូលនឹងនាយសំពៅឱ្យនៅមើលល្ខោនក្នុងមហោស្រពមួយយប់សិន ហើយទ្រង់មានព្រះរាជបញ្ជាឱ្យមហាតលិកទាំងពីរនាក់នៅយាមសំពៅក្នុងរាត្រីនោះ។ យប់នោះព្រះនាង **កេសិនី** ផ្ទំក្នុង សំពៅ។ ទ្រង់ព្រះសុបិនថា ព្រះនាងបានជួបជុំព្រះស្វាមី និងព្រះរាជបុត្រដោយសេចក្ដីរីករាយ។ ហើយមានបុរសពីរនាក់យកផ្កាឈូកមកថ្វាយព្រះស្វាមីៗប្រទានមកឱ្យព្រះនាងៗសៀតលើព្រះកាណ៌ ហើយទ្រង់សោយលំអងផ្កាឈូកនោះ។



At that moment the merchant went to do business at Takaksila Kingdom. The king asked him to stay one night to see the Royal Opera in the theater, and he ordered the two servants to guard the junk that night. At that time, Princess Kesiny was sleeping in the junk, dreaming that she happily met her husband and children and that there was two men giving lotuses to her husband and then he gave them to her. She put them on her ears, while her husband ate the pollen.

លុះព្រះនាងតើនឡើងទ្រង់ព្រះកន្សែងរំពឹងគិតក្នុងព្រះទ័យថា "ស្អែកនេះខ្ញុំប្រហែលជាបានជួបជុំព្រះស្វាមី និងកូនទាំងពីររបស់ខ្ញុំវិញហើយ"។ លុះដល់ពេលអាធ្រាត្រ **ជ័យទត្ត** ក៏លង់លក់ទាំងអង្គុយ **ជ័យសែន** ក៏ដាស់ប្អូនជារឿយៗ។ **ជ័យទត្ត** មិនចង់ឱ្យការងងុយគ្របសង្កត់ពេកទេ ក៏បាននិយាយនឹងបងថា "សូមបងនិយាយរឿងព្រេងអ្វីមួយឱ្យខ្ញុំស្ដាប់បន្ដិចមក" បងប្រាប់ប្អូនថា "បងមិនចេះនិយាយរឿងព្រេងទេ តែបងដឹងរឿងខ្លះៗដែលយើងព្រាត់ប្រាសអំពីឪពុកម្ដាយរបស់យើង"។



When she was awaked, she cried and thought of herself, "Tomorrow I may be able to reunite my husband and children." At midnight Cheytot sat sleeping, but Cheysen woke him up often. Cheytot did not want to be sleepy any more, so he said to his brother, "Please tell me a folk tale." His elder brother replied, "I don't know any folk tale, but I know a story about the time when our families were separated."



**ជ័យទត្ត** សួរបងទៀតថា "ចុះឪពុកម្ដាយយើងសព្វថ្ងៃនេះ?" **ជ័យសែន** ឆ្លើយថា "ពួកគាត់មិនមែនជាឪពុកម្ដាយបង្កើតរបស់យើងទេ ចាំបងនិយាយឱ្យឯងស្ដាប់។

ដើមឡើយឪពុកម្ដាយយើងជាស្ដេចសោយរាជ្យនៅចម្បាកនគរ។ ព្រះអនុជរបស់ទ្រង់ព្រះនាម **អសុភមិត្រ** ជាឧបរាជបានដណ្ដើមរាជបល្ល័ង្កពីព្រះបិតាយើង។

ព្រះបិតាក៏នាំពួកយើងតូចៗរំដោះខ្លួនរត់ចោលព្រះនគរទាំងយប់លេច វាលចូលព្រៃដរាបដល់ទន្លេមួយ ព្រះវរបិតានាំព្រះមាតាហែលឆ្លងទន្លេទៅទុកនៅត្រើយម្ខាង។ បន្តិចមកមានព្រានមច្ឆាអុំទូកចូលមកចាប់យើងទាំងពីរនាក់យកទៅចិញ្ចឹមរហូតដល់ធំ។ ហើយនាំពួកយើងមកថ្វាយព្រះចៅក្រុងតក្កសិលានេះឯង"។ **ជ័យទត្ត** សួរទៀតថា "តើព្រះបិតាមាតាយើងមានព្រះនាមអ្វីទៅ?" **ជ័យសែន** ផ្តល់ចម្លើយថា "ព្រះមាតាយើងព្រះនាម **កេសិនីទេវី** ឯព្រះបិតាបងមិនហ៊ានចេញព្រះនាមព្រះអង្គទេ"។ ព្រោះតែប្អូនទទូចសួរខ្លាំងពេក បងក៏មិនលាក់ប្អូនតទៅទៀតដែរ បងបានប្រាប់ប្អូនថា "សូមឯងកុំនិយាយចេញឈ្មោះព្រះអង្គឱ្យសោះ ព្រះបិតាយើងព្រះនាមព្រះបាទ **ក្រុងសុភមិត្រ** គឺជាស្តេចក្រុងតក្កសិលានេះឯង"។

"Who are our present parents?" asked Cheytott. Cheysen replied, "They are now our natural parents. Let me tell you what happened."
"At the previous time, our parents were the king and queen at Champak Kingdom. Our father's younger brother, AkSopheakmit, who was his lord, seized the throne from him. Our father took both of us to escape from the kingdom overnight, through the fields, the jungles and then arrived at a river. Our father brought our mother to the other side. Not so longer after they left us, the fishermen rowed his boat past by and saw us, so they caught us to adopt until we grew up. Then, they sent us to this king of Takaksila Kingdom." Cheytot asked, "What are our parents' names?"
Cheysen answered, "Our mother's name is Kesiny, but I am afraid of telling about our father's name." Since his brother kept asking about the father's name, Cheysen agreed to tell him.
"Don't speak out of his name," he told his younger brother, "Our father's name is Krong Sopheakmit, who is the king of this kingdom."



ឯព្រះនាង **កេសិនី** នៅក្នុងសំពៅបានឮសូរសព្ទសំដីនៃបុរសទាំងពីរ និយាយឆ្លើយឆ្លងគ្នាដូច្នោះ ព្រះនាងទ្រង់ជ្រាបច្បាស់ថា ពួកគេពិតជាបុត្រកំសត់របស់ទ្រង់ហើយៗព្រះនាងស្ទុះចេញមករកកំលោះទាំងពីរ ទ្រង់ព្រះកន្សែងសោយសោក ទ្រង់ឱបព្រះរាជបុត្ររន្ធត់ក្នុងព្រះទ័យក្រៃលែង ព្រះនាងមានព្រះបន្ទូលថា "**ជ័យសែន ជ័យទត្ត** កូនមាសម្ដាយៗនេះហើយឈ្មោះ **កេសិនីទេវី** ចូរកូនស្គាល់ម្ដាយចុះ កូនកុំទៅណាចោលម្ដាយអី"។ **ជ័យសែន ជ័យទត្ត** បន្ទាប់ពីបានដឹងជាក់ច្បាស់ជាព្រះមាតាពិតប្រាកដហើយ ក៏នាំគ្នាស្ទុះទៅឱបជើងព្រះមាតា ទ្រង់តក់ស្លុតរន្ធត់ក្រៃលែង។ គ្រានោះម្ចាស់សំពៅមកទាន់ឃើញដូច្នេះ ក៏នាំសេចក្ដីនេះក្រាបទូលព្រះចៅក្រុងតក្កសិលាដោយចោទប្រកាន់ថា កំលោះទាំងពីរនាក់នេះបានលួចមានសាហាយស្មន់នឹងប្រពន្ធរបស់ខ្លួន។

Preah Neang Kesiny, who was in the junk, heard what the both young men talked about; she realized that they must be her pitiful children. She hurriedly came out to them, weeping and wailing and then she embraced them tightly and said, "Cheysen, Cheytot, my dear sons, it is me, Kesinytevy, your mother. Don't leave me, my sons." Cheysen and Cheytot, after realizing that she was their natural mother, went to hold the legs of their mother who was full of shock and surprise. Meanwhile, the merchant saw such activities, he went back to tell the king of Takaksila, accusing the both young men of having sex with his wife.

ព្រះចៅក្រុងតក្កសិលាទ្រង់ពិរោធជាខ្លាំង ក៏ត្រាស់ប្រើពេជ្ឈឃាតចាប់ពួកគេយកទៅពិឃាតបង់។ ឯពេជ្ឈឃាតក៏ចាប់ចងពួកគេវាយដំឥតត្រាប្រណី ហើយនាំចេញទៅពិឃាតតាមព្រះរាជអាជ្ញា។ ជួនជាកាលណោះមានបុរោហិតម្នាក់ជាអ្នកមានប្រាជ្ញាឃើញពួកគេបណ្ដើរអ្នកទោសទៅសម្លាប់ដូច្នោះ ទើបចូលទៅក្រាបទូលស្ដេចថា "តើព្រះអង្គបានជំនុំពិចារណាទោសរួចហើយឬនៅ?" ទ្រង់ត្រាស់ថា "មិនទាន់ជំនុំជំរះទេ"។



ក៏ទ្រង់បញ្ជាពេជ្ឈឃាតឱ្យនាំពួកគេចូលមកជំនុំជំរះវិញសិន។ ហើយព្រះអង្គបញ្ជាសេនាឱ្យទៅនាំប្រពន្ធនាយសំពៅមកទីជំនុំភ្លាម។ គ្រាន់តែទ្រង់ទតឃើញព្រះមហេសីភ្លាម បេះដូងពោរពេញដោយក្តីតក់ស្លុតរន្ធត់រកថ្លែងអ្វីពុំកើត។

The king then was absolutely furious. He ordered the executioners to kill the young men. The executioners tied them up with rope and cruelly beat them and took them out to be killed by the king's order. Accidentally, a clever Brahma priest, who saw the executioners taking the prisoners to be executed, went to the king. "Have you judged them properly?" asked the priest. "Not yet," replied the king. The king, then, ordered the executioners to get them back for the judgment and told a servant to take the merchant's wife to the court room. Not sooner did the king see his wife than he was absolutely shocked.





ព្រះអង្គស្ទុះទៅឱបព្រះមហេសី ទ្រង់ព្រះកន្សែងសោយសោកមហិមា។ ទ្រង់អាណិតអាសូរចំពោះព្រះរាជបុត្រកំសត់លើសលន់ពន់ប្រមាណ។ ហើយក្សត្រាក្សត្រីទាំងបួនអង្គក៏បានជួបជុំគ្នាយំសោកដោយការកំសត់កម្រ និងការព្រាត់និរាសគ្នាអស់កាលដ៏យូរ។ ស្តេច **ក្រុងសុភមិត្រ** បានជួបជុំមហេសី និងព្រះរាជបុត្របណ្តូលព្រះរាជហឫទ័យប្រកបដោយព្រះទ័យសោមនស្សរីករាយពន់ពេក។ នៅទីបំផុត អាមាត្យសព្វមុខមន្ត្រី និងសេនាយោធាគ្រប់លំដាប់បានរៀបក្បួនដង្ហែក្សត្រាក្សត្រីទាំងបួនអង្គចូលមកក្នុងព្រះរាជវាំង។

The king went to embrace his wife, weeping and wailing so much. He felt extremely sympathetic towards his poor sons. They all were reunited and sobbed about hardship and long separation. King Sopheakmit enthusiastically met his wife and children.Finally, the royal servants, officials and all soldiers prepared a procession to bring the king, queen and their sons to the royal palace.

ព្រះបាទ **ក្រុងសុភមិត្រ** ទ្រង់បានជួបជុំព្រះអគ្គមហេសី ហើយទ្រង់លើក **ជ័យសែន** ជាឧបរាជ **ជ័យទត្ត** ជាសេនាបតីនៅនគរតក្កសិលានេះ។ ក្សត្រាក្សត្រីទាំងបួនអង្គស្ថិតនៅក្នុងរាជសម្បត្តិអស់កាលជាអង្វែងតទៅ។

**ចប់**




King Sopheakmit met his wife and appointed Cheysen a lord and Cheyteat a supreme commander in the kingdom of Takaksila. They all reigned that kingdom forever.

**The End**

**Loyalty is worth more than money**